ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
គណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍
លេខ: ០៧៨ កប/គបអ

គណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍
សូមគោរពជូន
ឯកឧត្តមទេសរដ្ឋមន្ត្រី និងជាប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

កម្មវត្ថុ: របាយការណ៍បូកសរុបលទ្ធផលការងារស្តីពីការបង្ការនិងការប្រយុទ្ធទប់ស្កាត់ការរាលដាលមេរោគអេដស៍ និងជំងឺអេដស៍រយៈពេល៩ខែ និងទិសដៅអនុវត្តត្រីមាសទី៤ឆ្នាំ២០១៤។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុខាងលើគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍សូមជម្រាបជូន **ឯកឧត្តមទេសរដ្ឋមន្ត្រី និងជាប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍** មេត្តាជ្រាបដូចខាងក្រោម:

ក- <u>លទ្ធផលការងារដែលសម្រេចបាន:</u>

I-<u>ការប្រជុំ និងការងារផ្សេងៗរបស់គណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ក្រសួង</u>

-សិក្ខាសាលាផ្សព្វផ្សាយកម្មវិធីផ្តល់ប្រឹក្សា និងធ្វើតេស្តឈាមរហ័សរកមេរោគអេដស៍ដោយការជោះឈាមពីចុងម្រាមដៃក្រោមអធិបតីភាព ឯកឧត្តមវេជ្ជបណ្ឌិត ហ៊ុយ ហានសុង រដ្ឋលេខាធិការ និងជាប្រធានគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដែលមានសិក្ខាកាមចូលរួមចំនួន ២៧ នាក់ (ស្ត្រី ១០នាក់) រៀបចំដោយលេខាធិការដ្ឋានអេដស៍សហការជាមួយសម្ព័ន្ធពាណិជ្ជកម្មកម្ពុជាប្រយុទ្ធនឹងជំងឺអេដស៍ (CBCA) នៅថ្ងៃទី៣០ ខែ ធ្នូ ឆ្នាំ២០១៣ នៅសាលប្រជុំនាយកដ្ឋានពេទ្យការងារ។

-ប្រជុំប្រចាំត្រីមាស ចំនួន ០៣ លើក របស់គណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ក្រោមអធិបតីភាពឯកឧត្តមវេជ្ជបណ្ឌិត ហ៊ុយ ហានសុង រដ្ឋលេខាធិការ និងជាប្រធានគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដែលមានសមាជិកចូលរួមចំនួន៧៣ នាក់(ស្ត្រី ១៥នាក់)នៅថ្ងៃទី២៣ ខែមករា ឆ្នាំ២០១៤ ថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០១៤ និងថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០១៤ នៅទីស្តីការក្រសួង។

-កិច្ចប្រជុំបូកសរុបលទ្ធផលការងារគម្រោងសុខភាពនៅកន្លែងធ្វើការប្រចាំឆ្នាំ ២០១៣ និងទិសដៅឆ្នាំ ២០១៤ ក្រោមអធិបតីភាព **ឯកឧត្តមវេជ្ជបណ្ឌិត ហ៊ុយ ហានសុង** រដ្ឋលេខាធិការ និងជាប្រធានគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈរៀបចំដោយលេខាធិការដ្ឋានអេដស៍សហការជាមួយអង្គការវ៉ាក់ នៅថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៤នៅទីស្តីការក្រសួង។

-កិច្ចប្រជុំពិភាក្សារៀបចំខ្លឹមសារ និងបែងចែកប្រធានបទបំណិនជីវិត នៅថ្ងៃទី១០ ខែមីនា ឆ្នាំ២០១៤ នៅលេខាធិការដ្ឋានអេដស៍ជាមួយអង្គការ CRS។

-កិច្ចប្រជុំពិគ្រោះយោបល់លើសេចក្តីព្រាងកម្មវិធីសិក្សាបំណិនជីវិតស្តីពីការអប់រំសុខភាពនៅកន្លែងសិក្សា នៅថ្ងៃទី២១ ខែមីនា ឆ្នាំ២០១៤ សហការជាមួយអង្គការ CRS។

-សិក្ខាសាលាបំណិនជីវិតស្តីពីការអប់រំសុខភាពនៅកន្លែងសិក្សា ដែលមានសិក្ខាកាមចូលរួមចំនួន១៥នាក់ (ស្រី៥នាក់)នៅថ្ងៃទី០៩-១០ ខែមេសា ឆ្នាំ២០១៤ នៅទីស្តីការក្រសួងសហការជាមួយអង្គការ CRS។

-បើកវគ្គបណ្តុះបណ្តាលកម្មវិធីសិក្សាបំណិនជីវិត ស្តីពីការអប់រំសុខភាពនៅកន្លែងសិក្សាដល់មន្ត្រីមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងមន្ត្រីនៅតាមវិទ្យាស្ថាន ឬមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រោមអធិបតីភាព **ឯកឧត្តមវេជ្ជបណ្ឌិត ហ៊ុយ ហានសុង** រដ្ឋលេខាធិការ និងជាប្រធានគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ចំនួន ០៨ខេត្ត (ខេត្តតាកែវ ខេត្តកំពត ខេត្តស្វាយរៀង ខេត្តពោធិ៍សាត់ ខេត្តបាត់ដំបង ខេត្តកំពង់ធំ ខេត្តសៀមរាប និងខេត្តកំពង់ចាម) សរុបសិក្ខាកាមចូលរួម ១២៣នាក់(ស្រី៣៥នាក់)។

-ចុះតាមដាន និងវាយតម្លៃលើដំណើរការបង្រៀនបំណិនជីវិត ស្តីពីការអប់រំសុខភាពនៅកន្លែងសិក្សានៅនៅមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈ និងវិទ្យាស្ថានពហុបច្ចេកទេសភូមិភាគតេជោសែន ចំនួន០៧ខេត្ត (ខេត្តតាកែវ ខេត្តកំពត ខេត្តស្វាយរៀង ខេត្តពោធិ៍សាត់ ខេត្តបាត់ដំបង ខេត្តកំពង់ធំ និងខេត្តសៀមរាប)។

-កិច្ចប្រជុំឆ្លងសេចក្តីព្រាងប្រកាសស្តីពីលក្ខខណ្ឌការងារ និងវិធានអនាម័យសន្តិសុខការងារនៃសហគ្រាស គ្រឹះស្ថាន ក្រុមហ៊ុនផ្នែកសេវាកម្មាន្តក្រោមអធិបតីភាពឯកឧត្តមបណ្ឌិតរដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដោយសហការជាមួយអង្គការ ILO នៅថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១៤ នៅទីស្តីការក្រសួង។

-សិក្ខាសាលាស្តីពីលក្ខខណ្ឌការងារ និងវិធានអនាម័យសន្តិសុខការងារ និងការបៀតបៀននៅកន្លែងធ្វើការសម្រាប់បុគ្គលិកផ្នែកធនធានមនុស្ស និងរដ្ឋបាលរោងចក្រចំនួន០៣វគ្គ ដែលមានសិក្ខាកាមចូលរួមចំនួន៦៨នាក់(ស្រី២៥នាក់) នៅថ្ងៃទី០៨ ទី០៩ និងទី៣១ ខែកក្កដា ឆ្នាំ២០១៤ នៅទីស្តីការក្រសួង។

-បើកវគ្គបណ្តុះបណ្តាលគ្រូបង្គោលស្តីពីការបង្ការ និងប្រយុទ្ធទប់ស្កាត់ការរាលដាលមេរោគអេដស៍ និងជំងឺអេដស៍ និងសុខភាពបន្តពូជសម្រាប់បុគ្គលិកគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ

ហាត្ថាកសិករ លីមីតធីត ដែលមានសិក្ខាកាមចូលរួមចំនួន ៤៩នាក់ (ស្ត្រី ១៥នាក់) នៅថ្ងៃទី ១៣-១៤ ខែកញ្ញា ឆ្នាំ២០១៤ ចំណាយថវិកាដោយគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុហាត្ថាកសិករ លីមីតធីត។

II-<u>ការប្រជុំ និងការងារផ្សេងៗរបស់គណៈកម្មការសម្របសម្រួលត្រីភាគី</u>(TCC)

-ប្រជុំចំនួន០២ លើកនៃគណៈកម្មការសម្របសម្រួលត្រីភាគី (TCC) ក្រោមអធិបតីភាព ឯកឧត្តមវេជ្ជបណ្ឌិត ហ៊ុយ ហានសុង រដ្ឋលេខាធិការ និងជាប្រធានគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ នៅថ្ងៃទី០៣ ខែកក្កដា ឆ្នាំ២០១៤ និងថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០១៤ នៅទីស្តីការក្រសួង។

III-<u>ការងារអប់រំអេដស៍ដល់ពលករត្រៀមចេញធ្វើការនៅប្រទេសកូរ៉ែ(៥មេរៀន)</u>

-បានផ្តល់ចំណេះដឹងពីស្ថានភាព មូលដ្ឋានគ្រឹះមេរោគអេដស៍ និងជំងឺអេដស៍ ជំងឺកាមរោគ គ្រឿងញៀន ការប្រើស្រោមអនាម័យដល់ពលករត្រៀមចាកចេញទៅធ្វើការនៅប្រទេសកូរ៉ែរៀបចំនៅវិទ្យាស្ថានជាតិពហុបច្ចេកទេសកម្ពុជា(NPIC) ចំនួន ២០ វគ្គ សរុប ៣.០៨៥ នាក់ ក្នុងនោះ ស្ត្រីចំនួន ៨០២ នាក់ និងបុរស ២.២៨៣ នាក់ (ឧស្សាហកម្ម ១.៤៥៦ នាក់ កសិកម្ម ១.៣៧៨ នាក់ និងសំណង់ ២៥១ នាក់))(ជូនភ្ជាប់នូវតារាងប្រៀបធៀបខាងក្រោម)។

IV-<u>ការងារចូលរួមប្រជុំ និងសិក្ខាសាលាជាមួយស្ថាប័នពាក់ព័ន្ធ</u>

-ចូលរួមកិច្ចប្រជុំក្រុមការងារបច្ចេកទេសថ្នាក់ជាតិ ចូលរួមដោយ ឯកឧត្តមវេជ្ជបណ្ឌិត ហ៊ុយ ហានសុង នៅថ្ងៃទី២២ ខែមករា ឆ្នាំ២០១៤ នៅអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។

-ចូលរួមកិច្ចប្រជុំពិគ្រោះយោបល់ស្តីពីការបង្កើតយន្តការឆ្ពោះទៅរកគោលនយោបាយជាតិគ្រប់គ្រងគ្រឿងស្រវឹងនៅកម្ពុជាចូលរួមដោយ ឯកឧត្តមវេជ្ជបណ្ឌិត ហ៊ុយ ហានសុង នៅថ្ងៃទី២៧ ខែមករា ឆ្នាំ២០១៤ នៅសាលសិក្ខាសាលាបណ្ណាល័យព្រឹទ្ធសភា។

-មន្ត្រីលេខាធិការដ្ឋានអេដស៍៤រូបចូលរួមសិក្ខាសាលារំលឹកដល់គ្រូបង្គោលរបស់គម្រោងស្តីពី "កន្លែងធ្វើការមានសុវត្ថិភាព និងសហគមន៍មានសុវត្ថិភាព" រៀបចំដោយអង្គការយែរកម្ពុជា នៅថ្ងៃទី២៧ ដល់២៨ ខែកុម្ភៈ ឆ្នាំ២០១៤ នៅភោជនីយដ្ឋានខ្មែរសុរិន្ទ។

-ចូលរួមកិច្ចប្រជុំលើកទី១ក្រុមការងារបច្ចេកទេសថ្នាក់ជាតិស្តីពីយុទ្ធសាស្ត្រទី៦ ចូលរួមដោយ លោកស្រី ឃុន សុខស៊ីណាក់ នៅថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១៤ នៅអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។

-ចូលរួមកិច្ចប្រជុំពិគ្រោះយោបល់ស្តីពីការផ្ទៀងផ្ទាត់លើរបាយការណ៍វឌ្ឍនភាពជាសកលឆ្លើយតបជាតិទូលំទូលាយ និងពហុវិស័យទៅនឹងការរាលដាលមេរោគអេដស៍ និងជំងឺអេដស៍នៅកម្ពុជា រៀបចំដោយអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ចូលរួមដោយលោក ជួរ អៀងលី នៅថ្ងៃទី ២១ ខែមីនា ឆ្នាំ២០១៤ នៅសណ្ឋាគារកាំបូឌីយ៉ាណា។

-ចូលរួមកិច្ចប្រជុំលើកកំពស់សកម្មភាពអប់រំនៅក្នុងរោងចក្រ(SAFE Meeting)ចូលរួមដោយ លោក អ៊ុំ វីរៈ នៅថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១៤ រៀបចំដោយអង្គការយែរកម្ពុជា នៅសណ្ឋាគារ

ឡាជាវ៉ាន់ដា។

-ចូលរួមកិច្ចប្រជុំសម្របសម្រួលថ្នាក់ជាតិស្តីពីការអនុវត្តបទអន្តរាគមន៍បង្ការមេរោគអេដស៍ និងជំងឺអេដស៍ក្នុងចំណោមបុរសស្រលាញ់បុរស និងស្រីស្រស់ ចូលរួមដោយលោកស្រី មៅ ធីតា នៅថ្ងៃទី២២ ខែឧសភា ឆ្នាំ២០១៤ នៅសណ្ឋាគារភ្នំពេញ។

-មន្ត្រីលេខាធិការដ្ឋានអេដស៍៤រូបចូលរួមសិក្ខាសាលាស្តីពីការរៀបចំផែនការយុទ្ធសាស្ត្រឆ្លើយតបទៅនឹងមេរោគអេដស៍និងជំងឺអេដស៍ឆ្ពោះទៅសម្រេចបាននូវគោលដៅសូន្យបីសម្រាប់ថ្នាក់ជាតិ រៀបចំដោយអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ នៅថ្ងៃទី០៣-០៦ ខែមិថុនា ឆ្នាំ២០១៤ នៅសណ្ឋាគារសោមាទេវីខេត្តសៀមរាប។

-ចូលរួមប្រជុំពេញអង្គអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ចូលរួមដោយ ឯកឧត្តមវេជ្ជបណ្ឌិត ហ៊ុយ ហានសុង នៅថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០១៤ នៅអគារមិត្តភាពទីស្តីការគណៈរដ្ឋមន្ត្រី។

-ចូលរួមកិច្ចប្រជុំប្រចាំត្រីមាសនៃក្រុមការងារបច្ចេកទេសថ្នាក់ជាតិសម្រាប់ក្រុមបុរសស្រលាញ់បុរស និងស្រីស្រស់ ចូលរួមដោយលោកស្រី ឃុន សុខសុីណាក់ នៅថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១៤ នៅសណ្ឋាគារអាំងទែកុងទីណង់តាល់។

-មន្ត្រីលេខាធិការដ្ឋានអេដស៍៣រូបចូលរួមវគ្គបណ្តុះបណ្តាលស្តីពីបច្ចុប្បន្នភាពឧបករណ៍តាមដាន និងវាយតម្លៃប្រចាំឆ្នាំដើម្បីបង្កើនប្រសិទ្ធភាពអនុវត្តប្រព័ន្ធតាមដាន និងវាយតម្លៃជាតិឆ្ពោះទៅសម្រេចបាននូវគោលដៅសូន្យបី រៀបចំដោយអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍នៅថ្ងៃទី០៨-១០ ខែកក្កដា ឆ្នាំ២០១៤ នៅភោជនីយដ្ឋានសួនអេដេន។

-ចូលរួមប្រជុំអន្តរក្រសួងដើម្បីពិភាក្សាលើសេចក្តីព្រាងច្បាប់ស្តីពីការត្រួតពិនិត្យផលិតផលថ្នាំជក់ ចូលរួមដោយលោក អ៊ុំ វីរៈ ថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១៤នៅក្រសួងសុខាភិបាល។

<u>ខ-ទិសដៅអនុវត្តបន្ត</u>

-ប្រជុំគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។

-ប្រជុំគណៈកម្មការសម្របសម្រួលត្រីភាគី (TCC)។

-ពិធីប្រគល់ប័ណ្ណសរសើរជូនដល់រោងចក្រ សហគ្រាស និងគ្រឹះស្ថានផ្នែកសេវាកម្មាន្តដែលមានស្នាដៃល្អក្នុងការអនុវត្តប្រកាសលេខ០៨៦ក្នុងការងារឆ្លើយតបការរាលដាលមេរោគអេដស៍/ជំងឺអេដស៍នៅកន្លែងធ្វើការ។

-ផ្សព្វផ្សាយប្រកាសស្តីពីលក្ខខណ្ឌការងារ និងវិធានអនាម័យសន្តិសុខការងារនៃសហគ្រាស គ្រឹះស្ថាន ក្រុមហ៊ុនផ្នែកសេវាកម្មាន្ត។

-បន្តអប់រំពីមេរោគអេដស៍និងជំងឺអេដស៍ដល់ពលករទៅធ្វើការនៅសាធារណរដ្ឋកូរ៉េនៅ (NPIC)។

-បន្តកិច្ចសហការជាមួយអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ (NAA) អង្គការ CRS អង្គការ ILO និងអង្គការ CARE ។

សេចក្តីដូចបានជម្រាបជូនខាងលើ សូម **ឯកឧត្តមទេសរដ្ឋមន្ត្រី** មេត្តាជ្រាបជារបាយការណ៍ដ៏ខ្ពង់ខ្ពស់។

សូម**ឯកឧត្តម**មេត្តាទទួលនូវការគោរពដ៏ជ្រាលជ្រៅអំពីខ្ញុំបាទ។

រាជធានីភ្នំពេញថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០១៤

ប្រធាន

ភេជ្ជ. ហ៊ុយ ហានសុខ

ចម្លងជូន:
-រដ្ឋលេខាធិការ
-អនុរដ្ឋលេខាធិការ
-អគ្គនាយកដ្ឋានរដ្ឋបាល-ការងារ-TVET
-ន.ផែនការ ស្ថិតិ និងនីតិកម្ម
-អាជ្ញាធរជាតិប្រឃុំទន្ទឹងជំអឺអេដស៍
-ឯកសារ-កាលប្បវត្តិ

តារាង: ការអប់រំមេរោគអេដស៍/ជំងឺអេដស៍

ល.រ	បរិយាយ	ភេទ	រយៈពេល៩ខែ ឆ្នាំ ២០១៤	រយៈពេល៩ខែ ២០១៣	ប្រៀបធៀប (%)
			១	២	៣=(១-២)/២
១	ការអប់រំមេរោគអេដស៍/ជំងឺអេដស៍ ដល់ពលករត្រៀមទៅធ្វើការនៅប្រទេសកូរ៉	សរុប	៣.០៨៥	២.៧៧៥	១១.១៧
		ស្រី	៨០២	៧៧៨	៣.០៨

ប្រភព៖ លេខាធិការដ្ឋានអេដស៍រយៈពេល៩ខែឆ្នាំ២០១៤